មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណកថាព័ត៌មាន ម.ស.ម.ក

## ភ្នំពេញ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥

## ម.ស.ម.ក សូមអំពាវនាវជាថ្មីម្តងទៀត ឲ្យមានកិច្ចពិគ្រោះយោបល់លើ សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») សោកស្តាយយ៉ាងខ្លាំងចំពោះការសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល («ច្បាប់អង្គការសមាគម») ទៅកាន់គណៈរដ្ឋមន្ត្រី ដែលសារព័ត៌មាន ឌឹ ខេមបូឌា ដេលី បានចុះផ្សាយ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពី «សេចក្តីព្រាងច្បាប់អាចំកំបាំងស្តីពីអង្គការសមាគម បានមកដល់ទីស្តីការគណៈរដ្ឋមន្ត្រី» ទំព័រទី ៣ ដែលនេះជាសញ្ញាបញ្ជាក់ថានឹងមិនមានការរៀបចំកិច្ចពិគ្រោះយោបល់ណាមួយ រវាងសង្គមស៊ីវិល និងអង្គនីតិប្រតិបត្តិនោះទេ។ ក្នុងសេចក្តីថ្លែងការណ៍រួម ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៥ ដែលមានអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិប្រមាណជិត ៣០០ ស្ថាប័នបានបង្ហាញការព្រួយបារម្ភរបស់ខ្លួនចំពោះកង្វះតម្លាភាពក្នុងដំណើរការអនុម័តច្បាប់ និងអំពាវនាវជាថ្មីម្តងទៀតឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈ។ ចំណុចដែលគួរឲ្យសោកស្តាយនោះគឺ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងឲ្យមានកិច្ចពិភាក្សាបែបស្ថាបនាយ៉ាងណាក្តី រដ្ឋាភិបាលបែរជាអះអាងពីគោលបំណងក្នុងការពន្លឿនដំណើរការអនុម័តច្បាប់អង្គការសមាគម ដោយមិនមានកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យពីតួអង្គសង្គមស៊ីវិលទៅវិញ។

សេចក្តីព្រាងច្បាប់អង្គការសមាគម ឆ្នាំ២០១១ មានបញ្ញត្តិមួយចំនួនដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់តួអង្គសង្គមស៊ីវិលជាតិ និងអន្តរជាតិ ក្នុងការអនុវត្តការងាររបស់ខ្លួនដោយគ្មានការជ្រៀតជ្រែក។ ម.ស.ម.ក សូមលើកជាថ្មីម្តងទៀតថា កាលពីឆ្នាំ២០១១ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថាការអនុម័តច្បាប់អង្គការសមាគម នឹងត្រូវពន្យារពេល ២ឆ្នាំ ទៀត ដើម្បីឲ្យរដ្ឋាភិបាល និងសង្គមស៊ីវិលអាចធ្វើការរួមគ្នាទៅលើសេចក្តីព្រាងច្បាប់ដែលភាគីទាំងសងខាង អាចទទួលយកបាន។ ទោះបីជាយ៉ាងនេះក្តី មិនមានកិច្ចពិគ្រោះយោបល់ណាមួយត្រូវបានរៀបចំឡើង តាំងពីពេលនោះមក។ កាលពីអតីតកាល អង្គការសង្គមស៊ីវិលបានធ្វើការជាដៃគូជាមួយរដ្ឋាភិបាល ដើម្បីស្វែងរកដំណោះស្រាយ

រួម។ អ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន ត្រូវបានរាយការណ៍ថា "នៅពេលដែលសេចក្តីព្រាងច្បាប់ទៅដល់រដ្ឋសភា នោះប្រជាពលរដ្ឋនឹងអាចមានឱកាសមើលច្បាប់នោះហើយ» ដែលនេះជាទង្វើផ្ទុយស្រលះទៅនឹងវិធីសាស្ត្រប៉ែបស្ថាបនា។ កិច្ចខិតខំប្រឹងប្រែងរួម ដើម្បីបង្កើនតម្លាភាពក្នុងដំណើរការតាក់តែងច្បាប់ គឺចាំបាច់ណាស់ ហើយអាចធ្វើទៅបាន ដូចដែលបានបង្ហាញក្នុងកិច្ចពិគ្រោះយោបល់នាពេលថ្មីៗនេះ ទាក់ទិននឹងសេចក្តីព្រាងច្បាប់ទទួលបានព័ត៌មាន និងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ដូច្នេះ មានការសង្ឃឹមថារដ្ឋសភា នឹងបង្ហាញឥរិយាបថស្រដៀងគ្នានេះក្នុងពេលខាងមុខ។ ម.ស.ម.ក សូមអំពាវនាវជាថ្មីម្តងទៀតថា រដ្ឋាភិបាលប្រជាធិបតេយ្យគួរតែឈប់ និងងាកមកពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលជាមុនសិន។

**នាយិកាប្រតិបត្តិ ម.ស.ម.ក អ្នកស្រី ចក់ សុភាព បានមានប្រសាសន៍ថា ៖**

*"កម្ពុជា ជាប្រទេសមួយដែលច្បាប់សំខាន់ៗ នៅតែបន្តអនុម័តដោយគ្មានកិច្ចពិគ្រោះយោបល់ជាមួយសាធារណជនឲ្យបានគ្រប់គ្រាន់ ដូចជាការអនុម័តច្បាប់កំណែទម្រង់ប្រព័ន្ធបោះឆ្នោត និងច្បាប់ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការ នាពេលថ្មីៗនេះជាដើម។ ថ្វីបើហាក់ដូចជាមានការប្តេជ្ញាចិត្តពីរដ្ឋាភិបាល ក្នុងការបង្កើតដំណើរការប្រជាធិបតេយ្យដែលមានតម្លាភាព និងមានការចូលរួម រួមមានការចែកផ្សាយសេចក្តីព្រាងច្បាប់ កិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយអង្គការសង្គមស៊ីវិល និងរបៀបវារៈផ្នែកច្បាប់ដែលស្របនឹងប្រយោជន៍សាធារណៈ តែការពិតជាក់ស្តែងបែរជាផ្ទុយទាំងស្រុងទៅវិញ។ ជាអកុសល ការគាំទ្រដល់សង្គមស៊ីវិលដែលចូលរួមយ៉ាងសកម្មក្នុងជីវភាពសាធារណៈ រួមទាំងក្នុងអំឡុងដំណើរការអនុម័តច្បាប់ មិនមែនជាអាទិភាពរបស់រដ្ឋាភិបាល លើកលែងតែដំណើរការនោះបម្រើផលប្រយោជន៍នយោបាយ ហើយចំណុចនេះ នឹងមានផលលំបាកធ្ងន់ធ្ងរទៅលើការអភិវឌ្ឍន៍ប្រជាធិបតេយ្យដ៏ល្អប្រសើរមួយនៅកម្ពុជា។ រដ្ឋាភិបាលគួរតែចាត់វិធានការជាបន្ទាន់ដើម្បីអាចឆ្ពោះទៅរកទិសដៅមួយនោះ ដូចបានលើកអនុសាសន៍ឡើងនៅក្នុងអំឡុងការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់លើកទីពីររបស់កម្ពុជា និងក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិដែលទើបនឹងចេញថ្មីៗនេះ។"*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមទូរសព្ទ +៨៥៥ ១១ ៩៤៣ ២១៣ ឬអ៊ីម៉ែល chaksopheap@cchrcambodia.org ឬ អ្នកស្រី ជរ ច័ន្ទធីតា អ្នកស្រាវជ្រាវជាន់ខ្ពស់ ម.ស.ម.ក តាមទូរសព្ទ +៨៥៥ ១២ ៥១៥ ៥០៦ ឬអ៊ីម៉ែល thyda@cchrcambodia.org។**

– ចប់ –

**បណ្ណាធិការះ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម ("OMCT") បណ្តាញទារុណកម្ម អែស អូ អែស, សមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធអ្នកសារព័ត៌មានអាស៊ីអាគ្នេយ៍ ("SEAPA") និងជាសមាជិកនៃ សម្ព័ន្ធពិភពលោកដើម្បីការចូលរួមរបស់ប្រជាពលរដ្ឋ ("CIVICUS") ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងបានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីការផ្លាស់ប្តូរសង្គម មកពី មជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យ ឃ្វីនស្លែន ក្នុងទីក្រុង ប្រ៊ីសបេន ប្រទេសអូស្ត្រាលី។